ធ្វើបច្ចុប្បន្នភាពដែលបានអនុម័តចុងក្រោយ៖ ថ្ងៃទី ១៩ កុម្ភៈ ២០២០
មានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១៥ មេសា ២០២០
បានពិនិត្យកែសម្រួលថ្ងៃទី ១៥ មេសា ២០២២

# គោលនយោបាយការការពាររបស់អង្គការឃែរអន្តរជាតិ

## ការការពារពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ

## ១. សេចក្តីថ្លែងការណ៍គោលនយោបាយ

អង្គការឃែរ ចាត់ទុកសេចក្តីថ្លៃថ្នូររបស់មនុស្ស គឺជាធាតុស្នូលនៃការងារជួយសង្គ្រោះ និងអភិវឌ្ឍន៍របស់ខ្លួន។ បេះដូងនៃកិច្ចខិតខំប្រឹងប្រែងរបស់អង្គការឃែរ ក្នុងការជះឥទ្ធិពលលើភាពក្រីក្រ និងយុត្តិធម៌សង្គមគឺការចូលរួមរបស់ខ្លួនជាមួយសហគមន៍ដែលបាត់បង់ឱកាស។ នៅអង្គការឃែរ យើងក៏ទទួលស្គាល់ពីទំនួលខុសត្រូវពិសេសដែលយើងមានដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងយុត្តិធម៌សង្គមនៅក្នុងរង្វង់អង្គការផ្ទាល់របស់យើងផងដែរ ក៏ដូចជាការក្សាកន្លែងការងារប្រកបដោយសុវត្ថិភាព និងការគោរព។ យើងទទួលស្គាល់ពីសារសំខាន់នៃវប្បធម៌ និងទំនួលខុសត្រូវរបស់អង្គការក្នុងការបង្កើតបរិយាកាសមួយប្រកបដោយសុវត្ថិភាព និងការគាំទ្រសម្រាប់បុគ្គលិក បណ្តាដៃគូ និងសហគមន៍ដែលយើងធ្វើការជាមួយ។

នៅអង្គការឃែរ យើងជឿជាក់ថាមនុស្សទាំងអស់មានសិទ្ធិរស់រានមានជីវិត មានសេរីភាពរួចផុតពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។ យើងជឿថាការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ ត្រូវបានផ្តោតលើក្រុមមនុស្សជាក់លាក់មួយចំនួនដោយសារតែវិសមភាព និងភាពងាយរងគ្រោះ ជាពិសេសជាបទពិសោធន៍ដែលបានជួបប្រទះដោយស្ត្រី មនុស្សពេញវ័យ និងកុមារងាយរងគ្រោះ។ យើងទទួលស្គាល់ថាមានវិសមភាពនៃសិទ្ធិអំណាចរវាងបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ ព្រមទាំងបុគ្គលដែលយើងសហការជាដៃគូ និងធ្វើការជាមួយតាមរយៈកម្មវិធីរបស់យើង និងរវាងបុគ្គលនៅក្នុងរង្វង់អង្គភាពរបស់យើងផងដែរ។ យើងរំពឹងថាសិទ្ធិអំណាចរបស់យើងនឹងមិនត្រូវយកទៅប្រើប្រាស់ដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ឬបង្កអន្តរាយដល់អ្នកដទៃនោះទេ។

អង្គការឃែរ ទទួលស្គាល់ថាយើងមានទំនួលខុសត្រូវក្នុងការការពារបុគ្គលទាំងឡាយដែលយើងធ្វើការជាមួយ និងអ្នកដែលបម្រើការឱ្យយើង។ ហើយយើងនឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារមិនឱ្យកើតមានឡើង។ យើងយកចិត្តទុកដាក់លើរាល់ការរាយការណ៍អំពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។ សកម្មភាពរបស់យើងទទួលបានព័ត៌មានច្បាស់លាស់ តាមរយៈវិធីសាស្រ្តផ្តោតលើជនរងគ្រោះដែលមានន័យថាសេចក្តីត្រូវការ និងបំណងប្រាថ្នារបស់ជនរងគ្រោះចង្អុលបង្ហាញនូវការឆ្លើយតបរបស់យើង ហើយជនរងគ្រោះនឹងត្រូវបានយកចិត្តទុកដាក់ប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរពហើយសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានឯកជនភាព និងជំនួយគាំទ្រត្រូវបានផ្តល់ជាអាទិភាពដល់ពួកគេ។

អង្គការឃែរ មានវិធីសាស្រ្តមិនអត់ឱនចំពោះការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។ យើងនឹងពិនិត្យពីការចោទប្រកាន់ និងធ្វើការស៊ើបអង្កេតដោយយកចិត្តទុកដាក់ ព្រមទាំងចាត់វិធានការដាក់វិន័យសមស្របនៅពេលដែលចាំបាច់ ដោយគិតគូរអំពីសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះស្របទៅតាមវិធីសាស្រ្តផ្តោតលើជនរងគ្រោះ។ យើងបញ្ជាក់យ៉ាងច្បាស់ថាការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារតាមគ្រប់រូបភាពដែលបានប្រព្រឹត្តដោយបុគ្គលិក ដៃគូរបស់យើង ឬបុគ្គលិកដែលពាក់ព័ន្ធផ្សេងទៀតចំពោះនរណាម្នាក់នឹងមិនត្រូវបានអត់ឱនឡើយ។

## ២. វិសាលភាពនៃការអនុវត្ត

គោលនយោបាយនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់របស់អង្គការឃែរ៖

- បុគ្គលិកអង្គការឃែរ រួមមានបុគ្គលិកទាំងអស់ នៃគ្រប់អង្គភាពទាំងអស់ របស់អង្គការឃែរអន្តរជាតិសមាជិក[1] អង្គការឃែរសម្ព័ន្ធសាខាអង្គការឃែរ និងការិយាល័យប្រចាំប្រទេសអង្គការឃែរ អន្តរជាតិ ។
- បុគ្គលិកពាក់ព័ន្ធរួមមានសមាជិកក្រុមប្រឹក្សាភិបាល អ្នកស្ម័គ្រចិត្ត អ្នកហាត់ការ ភ្ញៀវ និងទីប្រឹក្សាជាតិ និងអន្តរជាតិ បន្ថែមលើអ្នកចុះកិច្ចសន្យាជារូបវន្តបុគ្គល និងជានីតិបុគ្គលរបស់អង្គភាពទាំងនេះ និងបុគ្គលិកពាក់ព័ន្ធ។ នេះរួមបញ្ចូលទាំងបណ្តាអង្គភាពក្រៅពីអង្គការឃែរ ព្រមទាំងបុគ្គលិករបស់ពួកគេ និងបុគ្គលដែលបានចុះកិច្ចព្រមព្រៀងសហការជាដៃគូផ្តល់ ឬទទួលជំនួយបន្ត ជាមួយអង្គការឃែរ ព្រមទាំងក្រុមអ្នកស្ម័គ្រចិត្តធ្វើការសហគមន៍ និងអ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្ត។[2]

គោលនយោបាយនេះអនុវត្តទាំងក្នុងអំឡុងពេល និងក្រៅម៉ោងធ្វើការធម្មតា។ ការធ្វើសកម្មភាពរបស់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធនៅខាងក្រៅម៉ោងធ្វើការដែលបង្ហាញថាមានលក្ខណៈផ្ទុយនឹងគោលនយោបាយនេះនឹងត្រូវបានចាត់ទុកថាការបំពានលើគោលនយោបាយនេះ។

និយមន័យបន្ថែមដែលទាក់ទងនឹងគោលនយោបាយនេះត្រូវបានដាក់បញ្ចូលក្នុងឧបសម្ព័ន្ធ ២ ។

## ៣. ការប្តេជ្ញាចិត្ត[3]ក្នុងកិច្ចគាំពាររបស់អង្គការឃែរ

### វប្បធម៌ ការដឹកនាំ និងគណនេយ្យភាពរបស់អង្គការ

៣.១ អង្គការឃែរ នឹងខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងសំដៅលើកកម្ពស់ បង្កើត និងថែរក្សានូវវប្បធម៌អង្គការចាត់តាំងមួយប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូបដែលធ្វើការជូន និងជាមួយអង្គការឃែរ ដែលក្នុងនោះរាប់បញ្ចូលទាំងបណ្តាដៃគូរបស់យើង និងសហគមន៍ដែលអង្គការឃែរ ធ្វើការជាមួយផងដែរ។ នៅគ្រប់ពេលទាំងអស់ គេរំពឹងថាក្រុមថ្នាក់ដឹកនាំរបស់អង្គការឃែរ នឹងលើកកម្ពស់តម្លៃនៃកិច្ចគាំពាររបស់អង្គការឃែរ ដោយស្វែងចេញពីការប្តេជ្ញាចិត្តរបស់អង្គការចំពោះសមភាព ភាពចម្រុះ និងការគោរពចំពោះអ្នកដទៃ។ អង្គការឃែរ នឹងបង្កើតបរិយាកាសមួយប្រកបដោយសុវត្ថិភាពក្នុងការដោះស្រាយចំពោះការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។

---

[1] បេក្ខជននិយោជិតអង្គការឃែរ ស្ថិតក្រោមទំនួលខុសត្រូវរបស់សមាជិកអង្គការឃែរ។

[2] នឹងមានតម្លៃតបស្នងខុសៗគ្នាចំពោះការអនុវត្តផ្នែកខ្លះនៃគោលនយោបាយនេះ និងគោលការណ៍សម្រាប់អ្នកធ្វើការស្ម័គ្រចិត្តដែលជ្រើសចេញពីក្នុងចំណោមសហគមន៍ដែលយើងធ្វើការជាមួយ។ ខណៈដែលការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ក៏ដូចជាការប្រើខុសគោលដៅនូវជំនួយមនុស្សធម៌ជានិច្ចកាលត្រូវបានហាមឃាត់ដូចដែលបានចែងយ៉ាងច្បាស់ក្នុងគោលនយោបាយនេះ ឆន្ទានុសិទ្ធិអាចនឹងយកមកប្រើជាចាំបាច់នៅក្នុងការអនុវត្តក្រមប្រតិបត្តិស្តីពីកិច្ចគាំពារចំពោះទំនាក់ទំនងផ្លូវភេទសម្រាប់អ្នកធ្វើការប្រភេទនេះ។ សូមមើលឧបសម្ព័ន្ធ ១: ក្រមប្រតិបត្តិស្តីពីកិច្ចគាំពាររបស់អង្គការឃែរ

[3] ការប្តេជ្ញាចិត្តត្រូវបានផ្អែកជាមូលដ្ឋានលើ និងពង្រីកបន្ថែមនូវកម្រងនៃការប្តេជ្ញាចិត្តដូចដែលបានចែងនៅក្នុងសេចក្តីថ្លែងការណ៍អំពីការប្តេជ្ញាចិត្តទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទទាំងដោយបុគ្គលិករបស់ និងមិនមែនរបស់អង្គការសហប្រជាជាតិ ចុះខែសីហា ២០០៨ ដែលបានអនុម័តដោយអង្គការឃែរ

៣.២ **អង្គការឃែរ នឹងរៀបចំយុទ្ធសាស្ត្រការការពារយ៉ាងជាក់លាក់មួយសម្រាប់អង្គការ** ជាមួយនឹងសមត្ថភាពដ៏មោះមុតនៅកម្រិតសមស្របជាមួយនឹងការបែងចែកធនធាននៅគ្រប់កម្រិតរបស់អង្គការ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។

៣.៣ **អង្គការឃែរ នឹងធានាត្រួតពិនិត្យ និងគណនេយ្យភាពកម្រិតខ្ពស់**ជុំវិញគោលនយោបាយការការពាររបស់ខ្លួន។យើងនឹងធ្វើកិច្ចការនេះតាមរយៈការតាមដាន និងត្រួតពិនិត្យការអនុវត្តការការពារ ព្រមទាំងស្វែងរកមតិត្រឡប់ពីបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ ដៃគូសហការ អ្នកចូលរួមគម្រោងកម្មវិធី និងសហគមន៍ដែលអង្គការឃែរ ធ្វើការជាមួយលើប្រសិទ្ធភាពនៃវិធានការកិច្ចគាំពាររបស់យើង។ យើងប្តេជ្ញារៀនសូត្រ និងកែលម្អជាបន្តដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។ យើងមានទំនួលខុសត្រូវ និងតម្លាភាពក្នុងការប្រាស្រ័យទាក់ទងកិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពការងាររបស់យើងទៅកាន់មជ្ឈដ្ឋានទាំងក្នុង និងក្រៅផ្សេងៗ រួមមានរចនាសម្ព័ន្ធអភិបាលកិច្ច និងដឹកនាំ បុគ្គលិក ម្ចាស់ជំនួយ ដៃគូ វិស័យផ្សេងៗ និងសហគមន៍នានាកាន់តែធំទូលាយ។ រាល់ព័ត៌មានដែលបានចែករំលែកនឹងត្រូវបានជូនដំណឹងដោយវិធីសាស្ត្រផ្តោតលើជនរងគ្រោះ និងការវាយតម្លៃហានិភ័យ។

## ការគ្រប់គ្រងធនធានមនុស្ស

៣.៤ **អង្គការឃែរ នឹងព្យាយាមជ្រើសរើសបុគ្គលិកឱ្យធ្វើការស្របទៅតាមចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់យើង និងអនុលោមតាមច្បាប់ជាធរមាន ទប់ស្កាត់ការបន្តជ្រើសរើស ឬដាក់ពង្រាយនូវជនល្មើសនៃអំពើបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។** យើងនឹងដាក់បញ្ចូលនូវទំនួលខុសត្រូវការងារសមស្របក្នុងចំណោមថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រង និងមុខតំណែងបុគ្គលិកផ្សេងទៀត។ ក្រុមថ្នាក់គ្រប់គ្រង និងធនធានមនុស្សនឹងធានាបាននូវដំណើរការជ្រើសរើសសម្រិតសម្រាំងបុគ្គលិកដ៏តឹងរឹងសម្រាប់បុគ្គលិកទាំងអស់ ជាពិសេសបុគ្គលិកដែលមានទំនាក់ទំនងផ្ទាល់ ឬប្រយោលជាមួយកុមារ និង/ឬ មនុស្សពេញវ័យដែលងាយរងគ្រោះ។ យើងអាចធ្វើបរិយាបន្ននៅក្នុងដំណើរការយោបល់ត្រឡប់សម្រាប់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ នូវការប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួនសំដៅបង្កើត និងរក្សាបាននូវបរិស្ថានមួយដែលជំរុញលើកកម្ពស់គោលនយោបាយនេះ និងក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ ព្រមទាំងដើម្បីទប់ស្កាត់ការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។

៣.៥ **អង្គការឃែរ នឹងធានាថាបុគ្គលិកទាំងអស់បានយល់ដឹងអំពីគោលនយោបាយកិច្ចគាំពារ សេចក្តីរំពឹងទុកអំពីការប្រកាន់ឥរិយាបថ និងការប្រព្រឹត្តរបស់យើង ព្រមទាំងវិធីរាយការណ៍ទង្វើខុសឆ្គង**ដោយដាក់បញ្ចូលសេចក្តីរំពឹងទុករបស់អង្គការឃែរ ស្តីពីការទប់ស្កាត់ការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានកុមារនៅក្នុងក្រមប្រតិបត្តិពាក់ព័ន្ធ ការតម្រង់ទិសបុគ្គលិកថ្មី ការបណ្តុះបណ្តាលលើកកម្ពស់ការយល់ដឹង និងវគ្គបំពាក់បំប៉ន ក៏ដូចជាតាមរយៈការទំនាក់ទំនងផ្ទៃក្នុងជាទៀងទាត់។

## បណ្តាដៃគូ

៣.៦ **អង្គការឃែរ នឹងលើកកម្ពស់ និងទាមទារឱ្យមានការការពារជាមួយបណ្តាដៃគូ។** អង្គការឃែរ នឹងធានាឱ្យមានការធ្វើការវាយតម្លៃឱ្យបានគ្រប់គ្រាន់លើគោលនយោបាយការការពារជាផ្នែកមួយនៃដំណើរការក្នុងការចាប់ដៃគូធ្វើការក្នុងភាពជាដៃគូ ជាមួយដៃគូថ្មី និងដៃគូដែលកំពុងមានស្រាប់។ យើងនឹងជ្រើសរើសដៃគូរបស់យើងដោយផ្អែកលើការប្តេជ្ញាចិត្តរបស់ពួកគេចំពោះសមភាព និងយុត្តិធម៌សង្គម គុណតម្លៃនៃអង្គភាពរបស់ពួកគេ និងពីរបៀបដែលពួកគេរក្សាការពារបុគ្គលិករបស់ខ្លួន និងអ្នកចូលរួមគម្រោងកម្មវិធីក៏ដូចជាលើភាពស័ក្តសមរបស់ពួកគេក្នុងការអនុវត្តការងារតាមតម្រូវការរបស់យើង។ យើងនឹងធានាថានៅពេលដែលចុះកិច្ចសន្យាសហការជាដៃគូ កិច្ចព្រមព្រៀងផ្តល់ ឬទទួលជំនួយបន្តកិច្ចព្រមព្រៀងទាំងនេះ៖ ក) ត្រូវដាក់បញ្ចូលគោលនយោបាយនេះជាឯកសារភ្ជាប់ ឬបើមិនដូច្នោះទេ អនុវត្តនូវនីតិវិធីយកចិត្តទុកដាក់ស្គាល់ និងត្រួតពិនិត្យសមស្របលើអ្នកទទួលគម្រោងបន្តរបស់ខ្លួនស្របតាមគោលនយោបាយនេះ ខ) ដាក់បញ្ចូលនូវភាសាសមស្របដែលតម្រូវឱ្យអង្គភាព និងបុគ្គលដែលចុះកិច្ចសន្យាទាំងនោះ ព្រមទាំងបុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់ពួកគេគោរពតាមក្រមប្រតិបត្តិ ដែលអនុលោមតាមបទដ្ឋាននៃគោលនយោបាយនេះ និង គ) បញ្ជាក់យ៉ាងច្បាស់ថាការខកខានរបស់អង្គភាព ឬបុគ្គលទាំងនោះ ប្រសិនបើមានក្នុងការចាត់វិធានការកិច្ចគាំពារប្រឆាំងនឹងការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ ធ្វើការស៊ើបអង្កេត និងរាយការណ៍ពីការចោទប្រកាន់ឱ្យបានទាន់ពេលវេលា ឬក្នុងការចាត់វិធានការកែតម្រូវនៅពេលដែលការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ឬការរំលោភបំពានលើកុមារបានកើតឡើង គឺជាមូលដ្ឋានសម្រាប់អង្គការឃែរ ក្នុងការបញ្ចប់កិច្ចព្រមព្រៀងទាំងនេះ។ យើងនឹងធ្វើការសហការដើម្បីកសាងសមត្ថភាពនៅក្នុងរង្វង់អង្គភាពនីមួយៗរបស់យើងសំដៅសម្រេចបានតាមការប្តេជ្ញាចិត្តយើងក្នុងកិច្ចគាំពារ។ យើងនឹងគោរពចំពោះបណ្តាដៃគូអ្នកផ្តល់ និងទទួលជំនួយបន្តរបស់យើង ហើយក្នុងករណីដែលអាចធ្វើទៅបាន និងចាំបាច់ផ្តល់ការគាំទ្រដល់ពួកគេដើម្បីមានជំនាញ និងសមត្ថភាពដើម្បីបំពេញនូវទំនួលខុសត្រូវរបស់ពួកគេស្របតាមគោលនយោបាយនេះ។ សម្រាប់អ្នកផ្គត់ផ្គង់ ទីប្រឹក្សា អ្នកចុះកិច្ចសន្យាឯករាជ្យ និងអ្នកដែលធ្វើការក្នុងវិស័យស្រដៀងគ្នាផ្សេងទៀត អង្គការឃែរ អាចដាក់បញ្ចូលគោលនយោបាយនេះភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរណាមួយ ឬបង្កើតលក្ខខណ្ឌសង្ខេបដែលមានចែងនៅក្នុងគោលនយោបាយនេះ ព្រមទាំងបទប្បញ្ញត្តិដែលបានចុះនៅក្នុងផ្នែកនេះ។

៣.៧ **អង្គការឃែរ នឹងសហការលើការការពារនៅក្នុងវិស័យនេះ** រួមទាំងជាមួយសហគមន៍នានា អង្គការ ម្ចាស់ជំនួយរដ្ឋាភិបាល បណ្តាញសង្គមស៊ីវិលសកល និងដៃគូក្នុងស្រុកផ្សេងទៀតដើម្បីជំរុញការអនុវត្តរបស់យើង ក៏ដូចជាចូលរួមចំណែកយ៉ាងទូលំទូលាយក្នុងកិច្ចប្រឹងប្រែងទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងការរំលោភបំពានលើកុមារ។

## ការធ្វើប្រតិបត្តិការការពារនៅក្នុងការងាររបស់យើង

៣.៨ **អង្គការឃែរ នឹងអនុវត្តធ្វើការវាយតម្លៃហានិភ័យលើការការពារ** ដើម្បីកំណត់ពីកត្តាហានិភ័យនៃការការពារ និងការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ និងរៀបចំឯកសារស្តីពីជំហាននានាដែលត្រូវចាត់ឡើងដើម្បីលុបបំបាត់ ឬកាត់បន្ថយហានិភ័យទាំងនេះ។

៣.៩ **អង្គការឃែរ នឹងដាក់បញ្ចូលវិធានការការពារទៅក្នុងគម្រោងកម្មវិធី និងវដ្តគម្រោងទាំងមូល។** យើងនឹងធ្វើឡើងតាមរយៈវិធីសាស្ត្ររៀបចំគម្រោងកម្មវិធីសហការរបស់យើងរាប់បញ្ចូលទាំងដៃគូ និងអ្នកចូលរួមគម្រោងកម្មវិធីរបស់យើងនៅគ្រប់

ដំណាក់កាលដើម្បីជំរុញការរៀបចំ ការត្រួតពិនិត្យ និងវាយតម្លៃឱ្យបានល្អប្រសើរនៅក្នុងគម្រោងកម្មវិធីរបស់យើង។ យើងមានគោលបំណងកំណត់ និងកាត់បន្ថយផលប៉ះពាល់ ឬហានិភ័យដែលកើតចេញពីគម្រោងកម្មវិធីរបស់យើង។

៣.១០ **អង្គការឃែរ នឹងធានាថាពហុយន្តការ ដើម្បីរាយការណ៍ពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារអាចដំណើរការបាន** និងឆ្លើយតបទៅនឹងតម្រូវការផ្សេងៗរបស់បុគ្គលនីមួយៗដែលមានបំណងរាយការណ៍ រាប់បញ្ចូលទាំងមនុស្សពេញវ័យ និងកុមារងាយរងគ្រោះបំផុតដែលប្រឈមនឹងការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ និងការរំលោភបំពានលើកុមារ សហគមន៍ដែលយើងធ្វើការជាមួយបណ្តាដៃគូរបស់យើង ព្រមទាំងបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ។ យើងនឹងជំរុញឱ្យអ្នកចូលរួមគម្រោងកម្មវិធីចូលរួមពាក់ព័ន្ធក្នុងការរៀបចំ ការត្រួតពិនិត្យ និងវាយតម្លៃយន្តការរាយការណ៍នៅតាមសហគមន៍។ យើងនឹងដាក់បញ្ចូលឯកសារនីតិវិធីនៃការរាយការណ៍ជាភាសាក្នុងតំបន់ដែលពាក់ព័ន្ធ។ យើងនឹងលើកកម្ពស់ការយល់ដឹងរបស់សហគមន៍អំពីការរំពឹងទុកចំពោះឥរិយាបថរបស់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធរបស់យើង ព្រមទាំងអំពីវិធីនៃការរាយការណ៍។ អង្គការឃែរ នឹងធានាថាបុគ្គលគ្រប់រូបដែលទទួលខុសត្រូវក្នុងការទទួលបានការរាយការណ៍យល់ពីរបៀបបំពេញភារកិច្ចរបស់ខ្លួន ព្រមទាំងចាត់ចែងដោះស្រាយប្រកបដោយសុវត្ថិភាព និងជាការសម្ងាត់។ យើងនឹងធ្វើការប្រកបដោយតម្លាភាពជាមួយជនរងគ្រោះជុំវិញការអនុវត្តកាតព្វកិច្ច ឬសកម្មភាពទាំងឡាយដែលអាចនឹងត្រូវធ្វើឡើងជាលទ្ធផល នៃការរាយការណ៍របស់ពួកគេ រួមទាំងការបញ្ជូនទៅកាន់តតិយជន។ រាល់ចំណាត់ការទាំងអស់នឹងត្រូវបានទទួលព័ត៌មានច្បាស់លាស់ តាមរយៈការវាយតម្លៃហានិភ័យទៅដល់បណ្តាអ្នកពាក់ព័ន្ធទាំងអស់។

## ឆ្លើយតប និងតាមដានរបាយការណ៍

៣.១១ **អង្គការឃែរ នឹងផ្តល់ការគាំទ្រ និងជំនួយទៅដល់អ្នកដាក់ពាក្យបណ្តឹង និងបុគ្គលដែលរងគ្រោះពី ការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ឬការរំលោភបំពានលើកុមារពីសំណាក់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ។** នេះរាប់បញ្ចូលទាំងការព្យាបាលវេជ្ជសាស្ត្រ ជំនួយផ្នែកច្បាប់ និងការគាំទ្រផ្នែកចិត្តសង្គម។ ជំនួយគាំទ្ររបស់យើងនឹងទទួលបានព័ត៌មានច្បាស់លាស់ តាមរយៈវិធីសាស្ត្រផ្តោតលើជនរងគ្រោះ និងការវាយតម្លៃពីលទ្ធភាពដែលអាចកើតឡើង និងហានិភ័យចំពោះអ្នកពាក់ព័ន្ធទាំងអស់។

៣.១២ **អង្គការឃែរ នឹងចាត់វិធានការសមស្របតាមលទ្ធភាពទាំងស្រុងរបស់អង្គការឃែរ ដើម្បីការពារបុគ្គលទាំងឡាយពីការសងសឹក** ក្នុងករណីដែលមានបទចោទប្រកាន់ពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារដែលពាក់ព័ន្ធនឹងបុគ្គលិកអង្គការឃែរឬបុគ្គលដែលពាក់ព័ន្ធត្រូវបានរាយការណ៍ដោយស្មោះត្រង់។

៣.១៣ **អង្គការឃែរ នឹងធានាថារាល់បទចោទប្រកាន់ពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារដោយបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធត្រូវបានពិនិត្យវាយតម្លៃហានិភ័យយ៉ាងហ្មត់ចត់ ហើយក្នុងករណីចាំបាច់ នឹងធ្វើការស៊ើបអង្កេត និង/ ឬបញ្ជូនទៅកាន់ស្ថាប័នផ្សេងទៀតដើម្បីធ្វើការស៊ើបអង្កេត ឬរាយការណ៍ទៅផ្នែកអនុវត្តច្បាប់។** ការស៊ើបអង្កេតរបស់អង្គការឃែរ នឹងត្រូវបានធ្វើឡើងយ៉ាងទាន់ពេលវេលា ប្រកបដោយសុវត្ថិភាព និងជំនាញវិជ្ជាជីវៈដោយបុគ្គលដែលទទួលបានការបណ្តុះបណ្តាល និងបទពិសោធន៍សមស្របក្នុងការស៊ើបអង្កេតអំពីបញ្ហារសើបនានា និងមានការយល់ដឹងគ្រប់គ្រាន់អំពីវិធីសាស្ត្រផ្តោតលើជនរងគ្រោះដោយផ្អែកលើយេនឌ័រ។ ការស៊ើបអង្កេតទាំងឡាយនឹងដាក់បញ្ចូលនូវការវាយតម្លៃហានិភ័យចំពោះបណ្តាអ្នកដែលពាក់ព័ន្ធទាំង

អស់។ យើងនឹងសហការជាមួយបណ្តាដៃគូរបស់យើងដើម្បីមានសមត្ថភាពក្នុងការស៊ើបអង្កេតបទចោទប្រកាន់ប្រហាក់ប្រហែលអំពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារពីសំណាក់បុគ្គលិករបស់ពួកគេ។

៣.១៤ **អង្គការឃែរ នឹងចាត់វិធានការយ៉ាងឆាប់រហ័ស និងសមស្របជាមួយបុគ្គលិកទាំងឡាយ ឬបុគ្គលិក ពាក់ព័ន្ធដែលបំពានលើគោលនយោបាយនេះដោយការប្រព្រឹត្តទង្វើបៀតបៀន កេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ព្រមទាំងរំលោភបំពានលើកុមារ។** នេះអាចរាប់បញ្ចូលទាំងចំណាត់ការផ្នែករដ្ឋបាល ឬវិន័យសកម្មភាពផ្លូវច្បាប់ និង/ឬការកសាងសំណុំរឿងបញ្ជូនទៅកាន់អាជ្ញាធរពាក់ព័ន្ធ ដើម្បីចាត់ការតាមនោះដែលរួមទាំងការផ្តន្ទាទោសពីបទព្រហ្មទណ្ឌនៅក្នុងប្រទេសដើមរបស់ជនល្មើសក៏ដូចជានៅក្នុងប្រទេសម្ចាស់ផ្ទះ។ រាល់ចំណាត់ការទាំងអស់នឹងត្រូវបានទទួលព័ត៌មានច្បាស់លាស់តាមរយៈវិធីសាស្រ្តផ្តោតលើជនរងគ្រោះ និងការវាយតម្លៃពីលទ្ធភាពដែលអាចកើតមាន និងហានិភ័យចំពោះបណ្តាអ្នកពាក់ព័ន្ធទាំងអស់។

## ៤. ក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ[4]របស់អង្គការឃែរ

សមត្ថភាពរបស់អង្គការឃែរ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួនអាស្រ័យលើកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈបុគ្គល និងការសហការគ្នារវាងបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ។ ដើម្បីសម្រេចបាននូវគោលដៅនេះ បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ត្រូវប្រកាន់ខ្ជាប់ និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈស្របតាមបទដ្ឋានខ្ពស់បំផុត ព្រមទាំងគោរពតាមគោលនយោបាយនានារបស់អង្គការឃែរ។ គោលនយោបាយនេះ កំណត់ពីកិច្ចគាំពារដែលត្រូវអនុវត្តដោយបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ដើម្បីការពារបុគ្គលគ្រប់រូបពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារពីសំណាក់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ។

ក្រមប្រតិបត្តិស្តីពីកិច្ចគាំពារនេះ មានគោលបំណងផ្តល់នូវមគ្គុទ្ទេសក៍ចង្អុលបង្ហាញមួយ សម្រាប់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធដើម្បីធ្វើការសម្រេចចិត្តដែលឆ្លុះបញ្ចាំងពីក្រមប្រតិបត្តិរបស់អង្គការឃែរ និងគុណតម្លៃស្នូលក្នុងន័យទូលាយនៅក្នុងជីវិតវិជ្ជាជីវៈ និងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ រាល់ការបំពានលើក្រមប្រតិបត្តិស្តីពីកិច្ចគាំពារនេះគឺជាបញ្ហាកង្វល់ដ៏ធ្ងន់ធ្ងរមួយ ហើយដែលអាចនាំទៅរកវិធានការវិន័យ ថែមទាំងការបញ្ឈប់ពីការងារផងដែរអនុលោមទៅតាមនីតិវិធីវិន័យរបស់សមាជិក និងសម្ព័ន្ធសាខានីមួយៗរបស់អង្គការឃែរ អន្តរជាតិ និងច្បាប់ជាធរមាន។ បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ត្រូវអាន និងចុះហត្ថលេខាលើក្រមប្រតិបត្តិស្តីពីកិច្ចគាំពារនេះ។[5]

## ៥- ទំនួលខុសត្រូវ

[4]ផ្អែកជាមូលដ្ឋានលើគោលការណ៍ស្នូលទាំងប្រាំមួយដកស្រង់ចេញពីព្រឹត្តិបត្រព័ត៌មានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីវិធានការពិសេសដើម្បីកិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (ST/SGB2003/13)

[5] និយោជិត និងបុគ្គលទាំងឡាយដែលបានចុះកិច្ចព្រមព្រៀងសហការក្នុងភាពជាដៃគូ កិច្ចព្រមព្រៀងផ្តល់ជំនួយ ឬទទួលជំនួយបន្តដែលអង្គការឃែរ អាចនឹងចុះហត្ថលេខាលើក្រមប្រតិបត្តិ និងបទដ្ឋាននានារបស់និយោជករបស់ពួកគេប្រសិនបើវាមានលក្ខណៈទូទៅស្របជាមួយនឹងបទដ្ឋានទាំងនេះ។

### ៥.១ បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់

បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់មានកាតព្វកិច្ចទប់ស្កាត់ រាយការណ៍ និងឆ្លើយតបចំពោះការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។ នេះគឺជាទំនួលខុសត្រូវរបស់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ក្នុងការប្រកាន់ខ្ជាប់នូវគោលនយោបាយកិច្ចគាំពារ និងក្រមប្រតិបត្តិស្តីពីកិច្ចគាំពាររបស់អង្គការឃែរ ។ បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ត្រូវអានគោលនយោបាយនេះ និងចុះហត្ថលេខាលើក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ ឬចុះហត្ថលេខាលើក្រមប្រតិបត្តិណាមួយដែលស្របតាម ឬយោងតាមគោលនយោបាយនេះ និងក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ។

### ៥.២ ប្រធានផ្នែក ប្រធានគ្រប់គ្រងផ្ទាល់ និងប្រធានផ្នែកធនធានមនុស្ស

ប្រធានផ្នែក ប្រធានគ្រប់គ្រងផ្ទាល់ និងប្រធានផ្នែកធនធានមនុស្សត្រូវធានាថាបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់មានការយល់ដឹង និងអនុវត្តតាមគោលនយោបាយកិច្ចគាំពាររបស់អង្គការឃែរ និងចុះហត្ថលេខាលើក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ ឬចុះហត្ថលេខាលើក្រមប្រតិបត្តិណាមួយដែលស្របតាម ឬយោងតាមគោលនយោបាយនេះ និងក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ។ ប្រធានផ្នែកធនធានមនុស្សក៏ទទួលខុសត្រូវផងដែរក្នុងការជ្រើសរើស និងដឹកនាំបុគ្គលិកប្រកបដោយសុវត្ថិភាពខ្ពស់ ខណៈដែលប្រធានផ្នែក និងប្រធានគ្រប់គ្រងផ្ទាល់ទទួលខុសត្រូវក្នុងការធានាបានថាបុគ្គលិកមានការយល់ដឹង និងចំណេះដឹងជ្រួតជ្រាបអំពីគោលនយោបាយនេះ ព្រមទាំងចំណុចបញ្ហានានាដែលលើកឡើងក្នុងនោះ។ ប្រធានផ្នែកត្រូវធានាថាបុគ្គលិកទាំងអស់ដែលមានតួនាទីជំនាញស្របតាមគោលនយោបាយនេះត្រូវមានបទពិសោធន៍ ការបណ្តុះបណ្តាល និងការគាំទ្រសមស្របសម្រាប់ពួកគេ រាប់បញ្ចូលទាំងបុគ្គលិកដែលទទួលខុសត្រូវក្នុងការទទួល និងដោះស្រាយបញ្ហារសើបដែលបានរាយការណ៍ និងបុគ្គលិកដែលទទួលខុសត្រូវក្នុងការស៊ើបអង្កេត។ ប្រធានផ្នែកនឹងធានាចំពោះការគ្រប់គ្រងការងាររបស់បុគ្គលិក ផ្តល់ការគាំទ្រចំពោះវប្បធម៌របស់អង្គការចាត់តាំង ប្រកបដោយគណនេយ្យភាព និងសុវត្ថិភាពដើម្បីទប់ស្កាត់ការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។

### ៥.៣ នាយក/តំណាងប្រចាំប្រទេស/ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ឃែរ នៅគ្រប់ប្រទេស/តំបន់

នាយក ឬតំណាងប្រចាំប្រទេសត្រូវផ្តល់ការណែនាំចង្អុលបង្ហាញច្បាស់លាស់ពីរបៀបដែលអង្គការនឹងខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងនៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ដើម្បីការពារបុគ្គលទាំងឡាយពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារក្នុងការអនុវត្តគម្រោងកម្មវិធីរបស់អង្គការឃែរ នៅក្នុងប្រទេស។ នាយកប្រចាំប្រទេសត្រូវធានាថាយន្តការរាយការណ៍តាមសហគមន៍ដែលសមស្របតាមវប្បធម៌ ប្រកបដោយសុវត្ថិភាព និងអាចដំណើរការបានត្រូវបានបង្កើតឡើង អនុវត្ត ពិនិត្យតាមដាន និងត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព។ នេះរាប់បញ្ចូលទាំងការលើកកម្ពស់ការយល់ដឹងជាមួយអ្នកចូលរួមគម្រោងកម្មវិធី ក៏ដូចជាបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធអំពីការការពារពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ និងរបៀបប្រើយន្តការរាយការណ៍។ នាយកប្រចាំប្រទេសដឹកនាំការងាររបស់អង្គការឃែរ ជាមួយដៃគូនៅក្នុងតំបន់សំដៅធានាបាននូវការគាំទ្រការវាយតម្លៃ និងការពិនិត្យតាមដានយ៉ាងត្រឹមត្រូវលើការប្តេជ្ញាចិត្តរបស់ដៃគូពាក់ព័ន្ធនឹងគោលនយោបាយនេះ។ នាយកប្រចាំប្រទេសក៏នឹងខិតខំប្រឹងប្រែងផងដែរដើម្បីធានាបាននូវការដោះស្រាយបណ្តឹង ហើយនីតិវិធីស៊ើបអង្កេតត្រូវបានអនុម័តរួមជាមួយនឹងនីតិវិធីវិន័យបុគ្គលិក

សមស្របតាមការចាំបាច់។ នាយកប្រចាំប្រទេសទទួលខុសត្រូវក្នុងការធានាថា សេវាគាំទ្រជនរងគ្រោះដែលសមស្រប និងប្រកបដោយគុណភាពល្អត្រូវបានធ្វើការស្រាវជ្រាវ និងធ្វើឱ្យមាននៅទីតាំងរបស់ខ្លួន។

## ៥.៤ សមាជិក[6] និងសម្ព័ន្ធសាខារបស់អង្គការឃែរ អន្តរជាតិ

នាយកថ្នាក់ជាតិរបស់បណ្តាសមាជិក និងសម្ព័ន្ធសាខារបស់អង្គការឃែរ ត្រូវទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយនេះ។ បណ្តាសមាជិក និងសម្ព័ន្ធសាខារបស់អង្គការឃែរ ត្រូវធានាថាគោលនយោបាយនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្រមប្រតិបត្តិរបស់ខ្លួន។ បណ្តាសមាជិក និងសម្ព័ន្ធសាខារបស់អង្គការឃែរ ត្រូវទទួលខុសត្រូវក្នុងការកំណត់ និងរៀបចំធនធានឱ្យបានសមស្របក្នុងការរៀបចំផែនការការងារ និងនីតិវិធីដើម្បីពង្រឹង និងប្រតិបត្តិគោលនយោបាយនេះ ក៏ដូចជាការត្រួតពិនិត្យ និងរាយការណ៍អំពីការអនុវត្តគោលនយោបាយនេះដោយប្រើសូចនាករ និងវិធីសាស្ត្រអនុវត្តន៍ស្របតាមបទដ្ឋានជាគន្លឹះ។ បណ្តាសមាជិក និងសម្ព័ន្ធសាខារបស់អង្គការឃែរ ត្រូវមាននីតិវិធីរាយការណ៍ និងស៊ើបអង្កេត ព្រមទាំងនីតិវិធីវិន័យបុគ្គលិកសម្រាប់បុគ្គលិករបស់ខ្លួនដែលបំពេញបន្ថែម និងគាំទ្រចំពោះនីតិវិធីរបស់ការិយាល័យប្រចាំប្រទេស។

សមាជិកដឹកនាំរបស់អង្គការឃែរ នឹងផ្តល់ការគាំទ្រចាំបាច់ដល់ការិយាល័យប្រចាំប្រទេស ដើម្បីធានាបានថាការិយាល័យប្រចាំប្រទេសមានជំនាញបុគ្គលិកដែលចាំបាច់ ការណែនាំថវិកាសម្រាប់ដាក់ឱ្យអនុវត្តគោលនយោបាយនេះ យន្តការរាយការណ៍ នីតិវិធីស៊ើបអង្កេត ជំនួយគាំទ្រដល់ជនរងគ្រោះ និងគោលការណ៍ណែនាំស្តីពីការរាយការណ៍អំពីការអនុវត្តគោលនយោបាយនេះ។

## ៥.៥. លេខាធិការដ្ឋានអង្គការឃែរ អន្តរជាតិ

លេខាធិការដ្ឋានអង្គការឃែរ អន្តរជាតិនឹងសម្របសម្រួលត្រួតពិនិត្យលើគោលនយោបាយនេះដោយការសហការជាមួយនឹងមន្ត្រីបង្គោលនៃបណ្តាសមាជិក និងសម្ព័ន្ធសាខារបស់អង្គការឃែរ ព្រមទាំងត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយស្របតាមក្របខណ្ឌពេលវេលាដែលកំណត់ក្នុងគោលនយោបាយ។ លេខាធិការដ្ឋានអង្គការឃែរ អន្តរជាតិនឹងធ្វើការត្រួតពិនិត្យ និងរាយការណ៍អំពីគោលនយោបាយនេះដោយប្រើប្រាស់ទិន្នន័យបទដ្ឋានអំពីគណនេយ្យភាពជាសកល។

## ៥.៦ ក្រុមប្រឹក្សារបស់ ឃែរ

ក្រុមប្រឹក្សានៃបណ្តាសមាជិក និងសម្ព័ន្ធសាខារបស់អង្គការឃែរ ព្រមទាំងក្រុមប្រឹក្សាភិបាលរបស់អង្គការឃែរ អន្តរជាតិទទួលខុសត្រូវចំពោះគោលនយោបាយកិច្ចគាំពារនេះ ហើយតម្រូវឱ្យមានការរាយការណ៍ពីថ្នាក់ដឹកនាំជាទៀងទាត់ស្តីពីការអនុវត្តគោលនយោបាយ និងហានិភ័យដើម្បីផ្តល់ព័ត៌មានដល់ការចង្អុលបង្ហាញរបស់ពួកគេសម្រាប់អង្គការ។

# ៦. គោលនយោបាយរណប

គោលនយោបាយនេះបំពេញបន្ថែមលើកម្រងបទដ្ឋានឥរិយាបថដែលបុគ្គលិកអង្គការឃែរ ទាំងអស់ត្រូវ ប្រកាន់ខ្ជាប់នៅក្នុង៖

[6] បេក្ខជនរបស់អង្គការឃែរ រក្សាស្ថិតក្រោមទំនួលខុសត្រូវរួមរបស់សមាជិករបស់ ឃែរ ចំពោះគោលនយោបាយ។

- ក្រមប្រតិបត្តិ និងក្រមសីលធម៌របស់អង្គការឃែរ អន្តរជាតិ
- គោលនយោបាយស្តីពីសមភាពយេនឌ័ររបស់អង្គការឃែរ អន្តរជាតិ
- គោលនយោបាយស្តីពីការផ្តល់ការយល់ព្រមលើសាវតា និងរូបភាពរបស់អង្គការឃែរ អន្តរជាតិ
- ក្រម ឬគោលនយោបាយពាក់ព័ន្ធបន្ថែមទៀតដែលកំណត់ដោយលេខាធិការដ្ឋាន អង្គការឃែរអន្តរជាតិ សមាជិកអង្គការឃែរ សម្ព័ន្ធសាខាអង្គការឃែរ និងការិយាល័យប្រចាំប្រទេសរបស់អង្គការឃែរអន្តរជាតិ។

គោលនយោបាយនេះក៏ជាការឆ្លើយតបចំពោះគណនេយ្យភាពរបស់អង្គការឃែរ ចំពោះសហគមន៍ដែលខ្លួនធ្វើការជាមួយផងដែរ ដូច្នេះវាត្រូវបានដាក់ឱ្យប្រតិបត្តិជាផ្នែកមួយនៃក្របខណ្ឌគណនេយ្យភាព កាន់តែទូលំទូលាយរបស់អង្គការឃែរអន្តរជាតិ។

## ឧបសម្ព័ន្ធ ១ - ក្រមប្រតិបត្តិ[7]ស្តីពីការការពាររបស់អង្គការឃែរ

សមត្ថភាពរបស់អង្គការឃែរ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ខ្លួនអាស្រ័យលើកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈបុគ្គល និងការសហការគ្នារវាងបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ។ ដើម្បីសម្រេចបាននូវគោលដៅនេះ បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ត្រូវប្រកាន់ខ្ជាប់ និងលើកកម្ពស់ក្រមសីលធម៌ និងវិជ្ជាជីវៈស្របតាមបទដ្ឋានខ្ពស់បំផុត ព្រមទាំងគោរពតាមគោលនយោបាយនានារបស់អង្គការឃែរ ។ គោលនយោបាយនេះកំណត់ពីកិច្ចគាំពារដែលត្រូវអនុវត្តដោយបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ដើម្បីការពារបុគ្គលគ្រប់រូបពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារពីសំណាក់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ។

ក្រមប្រតិបត្តិស្តីពីការការពារនេះ មានគោលបំណងផ្តល់នូវមគ្គុទ្ទេសក៍ចង្អុលបង្ហាញមួយ សម្រាប់បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធដើម្បីធ្វើការសម្រេចចិត្តដែលឆ្លុះបញ្ចាំងពីក្រមប្រតិបត្តិរបស់អង្គការឃែរ និងគុណតម្លៃស្នូលក្នុងន័យទូលាយនៅក្នុងជីវិតវិជ្ជាជីវៈ និងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។ រាល់ការបំពានលើក្រមប្រតិបត្តិស្តីពីកិច្ចគាំពារនេះគឺជាបញ្ហាកង្វល់ដ៏ធ្ងន់ធ្ងរមួយ ហើយដែលអាចនាំទៅរកវិធានការវិន័យថែមទាំងការបញ្ឈប់ពីការងារផងដែរអនុលោមទៅតាមនីតិវិធីវិន័យរបស់សមាជិក និងសម្ព័ន្ធសាខានីមួយៗរបស់អង្គការឃែរ អន្តរជាតិ និងច្បាប់ជាធរមាន។ បុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ត្រូវអាន និងចុះហត្ថលេខាលើក្រមប្រតិបត្តិ[8]ស្តីពីកិច្ចគាំពារនេះ។

ក្នុងនាមជាបុគ្គលិកអង្គការឃែរ ឬបុគ្គលិកពាក់ព័ន្ធ ខ្ញុំនឹង៖

១. បង្កើត និងថែរក្សានូវវប្បធម៌មួយប្រកបដោយសុវត្ថិភាព និងសមធម៌សំដៅទប់ស្កាត់ និងប្រឆាំងចំពោះការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារ។[9]

២. ប្រព្រឹត្តចំពោះបុគ្គលគ្រប់រូបប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរពព្រមទាំងតតាំងនឹងឥរិយាបថ និងអាកប្បកិរិយាទាំងឡាយដែលផ្ទុយនឹងគោលនយោបាយកិច្ចគាំពារ និងក្រមប្រតិបត្តិស្តីពីកិច្ចគាំពាររបស់អង្គការឃែរអន្តរជាតិ។

៣. រាយការណ៍ភ្លាមៗនូវរាល់បញ្ហាកង្វល់នានាដែលខ្ញុំមានទាក់ទងនឹងករណីបំពាន ដែលអាចកើតមានលើគោលនយោបាយកិច្ចគាំពារ ឬក្រមប្រតិបត្តិស្តីពីកិច្ចគាំពាររបស់អង្គការឃែរអន្តរជាតិ មិនថាដោយបុគ្គលិកអង្គការឃែរ ឬដោយបុគ្គលិកដែលពាក់ព័ន្ធទេ។ ខ្ញុំយល់ថាការខកខានមិនបានរាយការណ៍នូវបញ្ហាកង្វល់ទាំងឡាយអាចនាំទៅដល់ការដាក់វិធានការវិន័យ។ ខ្ញុំសូមធានាថាខ្ញុំមានការយល់ដឹងពីជម្រើសផ្សេងៗដែលខ្ញុំមានក្នុងការរាយការណ៍ និងថានៅពេលដែលខ្ញុំរាយការណ៍ពីបញ្ហាកង្វល់ ឬបទចោទប្រកាន់ណាមួយ នោះខ្ញុំនឹងរក្សាវាជាការសម្ងាត់។[10]

៤. ចែករំលែកព័ត៌មានរសើបដែលខ្ញុំអាចដឹងទាក់ទងនឹងបញ្ហាកង្វល់ពីការបៀតបៀន ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ឬការរំលោភបំពានលើកុមារតាមរយៈជម្រើសរាយការណ៍ដែលខ្ញុំមាន មិនថាពាក់ព័ន្ធនឹងបុគ្គលិក ឬអ្នកចូលរួមគម្រោងកម្មវិធី ឬបុគ្គលផ្សេងទៀតនៅក្នុងសហគមន៍ដែលអង្គការឃែរ ធ្វើការជាមួយនោះទេ។ ខ្ញុំយល់ថាជាការគោរពចំពោះសេចក្តី

---

[7] ផ្អែកជាមូលដ្ឋានលើគោលការណ៍ស្នូលទាំងប្រាំមួយដកស្រង់ចេញពីព្រឹត្តិបត្រព័ត៌មានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីវិធានការពិសេសដើម្បីកិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (ST/SGB/2003/13)

[8] និយោជិត និងបុគ្គលទាំងឡាយដែលបានចុះកិច្ចព្រមព្រៀងសហការក្នុងភាពជាដៃគូ កិច្ចព្រមព្រៀងផ្តល់ជំនួយ ឬទទួលជំនួយបន្តដែលអង្គការឃែរ អាចនឹងចុះហត្ថលេខាលើក្រមប្រតិបត្តិ និងបទដ្ឋាននានារបស់និយោជករបស់ពួកគេប្រសិនបើវាមានលក្ខណៈទូទៅស្របជាមួយនឹងបទដ្ឋានទាំងនេះ។

[9] អគ្គលេខាធិការអង្គការសហប្រជាជាតិ (ទំព័រទី ៣)

[10] ដូចយោងខាងលើ

ថ្លៃថ្នូរ និងសុវត្ថិភាពរបស់អ្នកទាំងឡាយដែលពាក់ព័ន្ធ វាចាំបាច់ណាស់ដែលខ្ញុំត្រូវរក្សាការសម្ងាត់អំពីបញ្ហាកង្វល់ ឬព័ត៌មានដែលខ្ញុំដឹង ហើយចែករំលែកព័ត៌មានដល់តែបុគ្គលិកក្នុងតួនាទីសមស្របដែលចាំបាច់ត្រូវដឹងព័ត៌មានទាំងនោះប៉ុណ្ណោះ។ ខ្ញុំដឹងថាការរំលោភលើគោលនយោបាយនេះអាចបង្កហានិភ័យដល់អ្នកដទៃដែលនឹងឈានដល់ការអនុវត្តនីតិវិធីវិន័យ។

៥. បង្ហាញដល់អង្គការឃែរ នូវសាលក្រមរដ្ឋប្បវេណី ឬការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយពាក់ព័ន្ធនឹងបទចោទប្រកាន់ដែលធ្វើឡើងចំពោះខ្ញុំពីបទបៀតបៀន កេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទលើជនណាម្នាក់។

៦. ជានិច្ចកាលត្រូវប្រាកដថាខ្ញុំមានវត្តមានមនុស្សពេញវ័យម្នាក់ទៀតនៅពេលធ្វើការជាមួយកុមារ។

៧. ជានិច្ចកាលត្រូវប្រាកដថាសម្រាប់គោលបំណងទាក់ទងនឹងការងារនៅពេលដែលខ្ញុំថតរូប ឬថតវីដេអូខ្ញុំនឹង៖

- គោរពតាមប្រពៃណីទំនៀមទម្លាប់ ឬការដាក់កំហិតលើការផលិតរូបភាពបុគ្គល
- ទទួលបានការយល់ព្រមត្រឹមត្រូវពីឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារមុនពេលថតរូប ឬថតវីដេអូកុមារដោយពន្យល់ពីការប្រើប្រាស់រូបថត ឬវីដេអូ។
- ធានាថារូបថត ភាពយន្ត វីដេអូ និង DVD បង្ហាញអំពីកុមារប្រកបដោយឥរិយាបថថ្លៃថ្នូរ និងការគោរព និងមិនស្ថិតក្នុងលក្ខណៈងាយរងគ្រោះ ឬរណប។
- ធានាថាកុមារស្លៀកពាក់គ្រប់គ្រាន់ និងមិនស្ថិតក្នុងកាយវិការណាមួយដែលបង្ហាញពីផ្លូវភេទ
- ធានាថារូបភាពគឺជាការតំណាងដោយស្មោះត្រង់តាមបរិបទ និងអង្គហេតុជាក់ស្តែង និង
- ធានាថាស្លាកឯកសារមិនបង្ហាញពីព័ត៌មានអត្តសញ្ញាណអំពីកុមារ ឧទាហរណ៍ ឈ្មោះ និងទីតាំងពិតប្រាកដ។

៨. ការពារ គ្រប់គ្រង និងប្រើប្រាស់ឱ្យបានត្រឹមត្រូវនូវធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភាររបស់អង្គការឃែរ និងមិនប្រើប្រាស់ធនធានរបស់អង្គការឃែរ រាប់បញ្ចូលទាំងការប្រើប្រាស់កុំព្យូទ័រ កាមេរ៉ា ទូរសព្ទចល័ត ឬប្រព័ន្ធបណ្តាញសង្គមដើម្បីកេងប្រវ័ញ្ច អូសទាញ ឬបៀតបៀនដល់អ្នកចូលរួមគម្រោងកម្មវិធី ឃែរ កុមារ ឬអ្នកផ្សេងទៀតនៅក្នុងសហគមន៍ដែលអង្គការឃែរ ធ្វើការជាមួយនោះទេ។ ខ្ញុំដឹងថាប្រការនេះមានន័យថាជាការហាមឃាត់បុគ្គលិកមិនឱ្យចូលមើល បង្ហាញ ឬបញ្ជូនការវាយលុក និង/ឬសម្ភារអាសអាភាសនៅលើឧបករណ៍អេឡិចត្រូនិកណាមួយដែលផ្តល់ ឬផ្គត់ផ្គង់ដោយអង្គការឃែរនោះទេ (ឧទាហរណ៍កុំព្យូទ័រ ថេប្លេត ទូរសព្ទ) នៅគ្រប់ពេល ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្ទាល់ខ្លួននៅលើប្រព័ន្ធបណ្តាញរបស់អង្គការឃែរ នៅកន្លែងធ្វើការ។

ក្នុងនាមជាបុគ្គលិកអង្គការឃែរ ឬបុគ្គលិកដែលពាក់ព័ន្ធ ខ្ញុំនឹងមិន៖

១. បៀតបៀន កេងប្រវ័ញ្ចផ្លូវភេទ ឬរំលោភបំពានជនណាម្នាក់ និងយល់ថាឥរិយាបថទាំងនេះគឺជាការប្រព្រឹត្តទង្វើមិនត្រឹមត្រូវ ហើយជាមូលដ្ឋាននៃវិធានការវិន័យរហូតឈានដល់ការបញ្ឈប់ពីការងារ។[11]

២. ចូលរួមពាក់ព័ន្ធតាមគ្រប់រូបភាពក្នុងសកម្មភាពផ្លូវភេទណាមួយ ឬបង្កើតទំនាក់ទំនងផ្លូវភេទ/រូបរាងកាយណាមួយជាមួយកុមារ (ជនអាយុក្រោម ១៨ ឆ្នាំ) ដោយមិនគិតពីអាយុសម្រាប់ផ្តល់ការយល់ព្រមនៅក្នុងស្រុក។ ខ្ញុំយល់ថាការមិនដឹង ឬការយល់ខុសពីអាយុរបស់កុមារមិនមែនជាលេសការពារខ្លួនទេ។[12]

---

[11] ដូចយោងខាងលើ

[12] ដូចយោងខាងលើ

៣. ប្តូរប្រាក់ ដោះដូរការងារ ទំនិញ ឬសេវាកម្មដើម្បីទទួលបានការរួមភេទ រាប់បញ្ចូលទាំងចំណង់ផ្លូវភេទ ឬទម្រង់ផ្សេងទៀតនៃអាកប្បកិរិយាដែលនាំឱ្យអាប់យស បន្ទាបបន្ថោក ឬមានចរិតកេងប្រវ័ញ្ច។ ខ្ញុំយល់ថាប្រការនេះមានន័យថាខ្ញុំមិនត្រូវទិញសេវាផ្លូវភេទពីជនណាម្នាក់នោះទេ ឬផ្លាស់ប្តូរជំនួយដែលបណ្តាលមកពីអ្នកចូលរួមកម្មវិធី / អ្នកទទួលផលសម្រាប់ការរួមភេទ[13] [14]

៤. ចូលរួមពាក់ព័ន្ធក្នុងសកម្មភាព ឬទំនាក់ទំនងផ្លូវភេទជាមួយអ្នកចូលរួម/អ្នកទទួលផលពីគម្រោងកម្មវិធី។ ខ្ញុំយល់ថាទំនាក់ទំនងបែបនេះត្រូវបានហាមឃាត់។ ខ្ញុំយល់ថាទំនាក់ទំនងបែបនេះផ្អែកលើមូលដ្ឋាននៃការប្រើខុសគោលដៅនូវតួនាទីរបស់ខ្ញុំ និងអំណាចមិនស្មើភាពជាសក្តានុពល ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការជឿជាក់ និងសុចរិតភាពនៃការងាររបស់អង្គការឃែរ ។ ខ្ញុំយល់ថាខ្ញុំត្រូវប្រកាសពីរាល់ទំនាក់ទំនងមុនៗដែលមានកន្លងមកជាមួយអ្នកចូលរួម/អ្នកទទួលផលពីគម្រោងកម្មវិធីទៅកាន់ប្រធានគ្រប់គ្រងផ្ទាល់ ឬប្រធានផ្នែកធនធានមនុស្សរបស់ខ្ញុំ។ ខ្ញុំនឹងស្វែងរកការណែនាំស្តីពីការហាមឃាត់នេះពីថ្នាក់គ្រប់គ្រងសមស្រប។[15] [16]

៥. ស្នើសុំសេវា ឬចំណង់ផ្លូវភេទពីអ្នកចូលរួមគម្រោងកម្មវិធីរបស់អង្គការឃែរ កុមារ ឬអ្នកផ្សេងទៀតនៅក្នុងសហគមន៍ដែលអង្គការឃែរ ធ្វើការជាមួយ ហើយនឹងមិនចូលរួមពាក់ព័ន្ធនៅក្នុងទំនាក់ទំនងដែលមានចរិតបៀតបៀន កេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទ។

៦. គាំទ្រ ឬចូលរួមតាមគ្រប់រូបភាពក្នុងសកម្មភាពកេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទជាតួយ៉ាងរូបភាពអាសអាភាសកុមារការជួញដូរមនុស្ស ឬអាពាហ៍ពិពាហ៍កុមារ។

៧. ទទួលយកកុមារឱ្យធ្វើការតាមផ្ទះ ឬប្រភេទការងារផ្សេងទៀតដែលមិនសមស្របតាមអាយុ ឬដំណាក់កាលលូតលាស់របស់ពួកគេដែលរំខានដល់ពេលវេលាសិក្សាអប់រំ និងសកម្មភាពកម្សាន្តរបស់ពួកគេ ឬដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យយ៉ាងខ្លាំងនៃការរងរបួស ឬការកេងប្រវ័ញ្ច។

៨. ប្រើភាសា ឬអាកប្បកិរិយាចំពោះកុមារដែលមិនសមរម្យ មានចរិតបៀតបៀន រំលោភបំពាន ស្រើបស្រាល មាក់ងាយ ឬមិនសមរម្យតាមវប្បធម៌។

---

[13] ដូចយោងខាងលើ

[14] អង្គការឃែរ មិនធ្វើការវិនិច្ឆ័យប្រឆាំងនឹងបុគ្គលទាំងឡាយដែលលក់ដូរផ្លូវភេទដើម្បីទទួលបានការតបស្នងជាប្រាក់ អំណោយ ឬការឧបត្ថម្ភជាសម្ភារផ្សេងៗទេ (ហៅថា "ប្រតិបត្តិការផ្លូវភេទ")។ ទោះជាយ៉ាងណា អង្គការឃែរ ហាមឃាត់និយោជិតរបស់ខ្លួន ឬបុគ្គលិកពាក់ព័ន្ធនានាមិនឱ្យទិញសេវាផ្លូវភេទដើម្បីទប់ស្កាត់មិនឱ្យកើតឡើងនូវការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។

[15] អង្គលេខាធិការអង្គការសហប្រជាជាតិ (ទំព័រទី ៣)

[16] ពេលខ្លះអង្គការឃែរ ទទួលយកអ្នកស្ម័គ្រចិត្តសហគមន៍ និងអ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្ត ព្រមទាំងទទួលស្គាល់ថានៅក្នុងកាលៈ ទេសៈទាំងនេះវាអាចនឹងកើតមានទំនាក់ទំនងផ្លូវភេទរវាងអ្នកស្ម័គ្រចិត្ត និងអ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្តជាមួយនឹងសមាជិកសហគមន៍ផ្សេងទៀត និងអ្នកចូលរួមគម្រោងកម្មវិធី ដែលក្នុងនោះរួមមានអាពាហ៍ពិពាហ៍កុមារដែលជាការបំពានលើគោលនយោបាយនេះ។ ព័ត៌មាន និងការបង្ហាញនូវទំនាក់ទំនងផ្លូវភេទ/អាពាហ៍ពិពាហ៍ដែលមានត្រូវបានធ្វើឡើងនៅមុនពេលការជ្រើសតាំងអ្នកស្ម័គ្រចិត្តសហគមន៍ និងអ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្ត ហើយប្រសិនបើ/នៅពេលដែលពិចារណាលើការបង្កើតទំនាក់ទំនងផ្លូវភេទ/អាពាហ៍ពិពាហ៍ធ្លាប់បានចុះកិច្ចសន្យារួចហើយជាមួយនឹងអង្គការឃែរ កំណត់ត្រាព័ត៌មានសម្ងាត់ត្រូវបានរក្សាទុកដោយថ្នាក់គ្រប់គ្រង។

## ឧបសម្ព័ន្ធ ២

## និយមន័យ

### កុមារ

កុមារគឺជាជនដែលមានអាយុក្រោម ១៨ ឆ្នាំដោយមិនគិតពីការកំណត់និយមន័យក្នុងស្រុករបស់ប្រទេសអំពីពេលដែលកុមារឈានទៅរកភាពពេញវ័យ។[17]

### មនុស្សពេញវ័យងាយរងគ្រោះ

ជនទាំងឡាយដែលមានអាយុចាប់ ១៨ ឆ្នាំដែល៖

- មិនអាចមើលថែ/ការពារខ្លួនបានពីការព្យាបាទ ឬការកេងប្រវ័ញ្ច ឬ
- ត្រូវបានចាត់ទុកថាមានហានិភ័យដោយសារយេនឌ័រ សុខភាពផ្លូវចិត្ត ឬផ្លូវកាយពិការភាពជាតិពន្ធុ អត្តសញ្ញាណសាសនា ទំនោរផ្លូវភេទ ស្ថានភាពសេដ្ឋកិច្ច ឬសង្គម ឬដោយសារគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗ។
- ស្ថិតក្នុងឋានៈតូចទាបដោយសារភាពលម្អៀងនៃអំណាចដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យ។

### ការបៀតបៀនផ្លូវភេទ[18]

ការបៀតបៀនផ្លូវភេទគឺជាការជំរុញផ្លូវភេទដែលមិនចង់បាន ការស្នើសុំចំណង់ផ្លូវភេទ ការប្រព្រឹត្តដោយពាក្យសម្ដី ឬរាងកាយ ឬកាយវិការមានចរិតផ្លូវភេទ ឬអាកប្បកិរិយាមានចរិតផ្លូវភេទផ្សេងទៀតដែលអាចត្រូវបានរំពឹង ឬយល់ថាអាចបង្កឱ្យមានការប្រមាថ ឬអាប់យសដល់អ្នកដទៃនៅពេលដែលការប្រព្រឹត្តនោះ ជ្រៀតជ្រែកទៅក្នុងការងារបង្កើតបានជាលក្ខខណ្ឌនៃការផ្ដល់ការងារ ឬបង្កើតបរិយាកាសការងារបំភិតបំភ័យអរិភាព ឬប្រមាថ។ បើទោះបីជាធម្មតាមានការពាក់ព័ន្ធនឹងលំនាំនៃឥរិយាបថ ប៉ុន្តែអាចមានទម្រង់ជាឧប្បត្តិហេតុតែមួយលើក។

### ការកេងប្រវ័ញ្ចផ្លូវភេទ[19]

ការកេងប្រវ័ញ្ចផ្លូវភេទមានន័យថាការរំលោភបំពានជាក់ស្ដែង ឬប៉ុនប៉ងរំលោភបំពានលើគោលជំហរនៃភាពងាយរងគ្រោះលម្អៀងនៃអំណាច ឬការកេងប្រវ័ញ្ចផ្លូវភេទ ឬការជឿទុកចិត្តក្នុងគោលបំណងផ្លូវភេទដែលមានជាអាទិ៍ ការកេងចំណេញប្រាក់ផ្នែកសង្គម ឬនយោបាយពីការកេងប្រវ័ញ្ចផ្លូវភេទលើបុគ្គលផ្សេងទៀត។

### ការរំលោភបំពានផ្លូវភេទ

ការរំលោភបំពានផ្លូវភេទមានន័យថាការរំលោភបំពានជាក់ស្ដែង ឬគំរាមកំហែងលើរាងកាយដែលមានចរិតផ្លូវភេទមិនថាដោយបង្ខំ ឬស្ថិតក្រោមលក្ខខណ្ឌមិនស្មើភាព ឬការបង្ខិតបង្ខំឡើយ។

---

[17] និយមន័យនៃពាក្យកុមារដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ (IASC) ស្ដីពីការអនុវត្តបទដ្ឋានប្រតិបត្តិអប្បបរមាសម្រាប់កិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទពីសំណាក់បុគ្គលិករបស់ និងមិនមែនរបស់អង្គការសហប្រជាជាតិចុះខែមីនា ២០១៣។

[18] និយមន័យនៃពាក្យ "ការបៀតបៀនផ្លូវភេទ" ដែលបានកំណត់ក្នុងព្រឹត្តិបត្រព័ត៌មានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្ដីពីការហាមឃាត់លើការរើសអើង ការបៀតបៀន រាប់បញ្ចូលទាំងការបៀតបៀនផ្លូវភេទ និងការរំលោភលើអំណាច (ST/SGB/2008/5)

[19] និយមន័យនៃពាក្យ "ការកេងប្រវ័ញ្ចផ្លូវភេទ" និង "ការរំលោភបំពានផ្លូវភេទ" ដែលបានកំណត់ក្នុងព្រឹត្តិបត្រព័ត៌មានរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្ដីពីវិធានការពិសេសដើម្បីកិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (ST/SGB2003/13)

**ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ** (ពាក់ព័ន្ធនឹងចំណុចមួយ ឬច្រើនខាងក្រោម)

### ក. ការរំលោភបំពានលើរាងកាយ

ការរំលោភបំពានលើរាងកាយកើតឡើងនៅពេលដែលជនណាម្នាក់បង្ករបួសស្នាម ឬគំរាមកំហែងបង្ករបួសស្នាមដល់កុមារដោយចេតនា។ ឧទាហរណ៍នេះអាចមានរូបភាពជាការទះកំផ្លៀង វាយ ដាល់ ចាប់អង្រួន ទាត់ធាក់ ដុតឱ្យរលាក រុញច្រាន ឬចាប់ទាញ។ ការរំលោភបំពានលើរាងកាយអាចជាទង្វើម្តង ឬច្រើនដង។ ជានិច្ចកាលវាមិនបន្សល់ទុកស្លាកស្នាម ឬរបួសដែលអាចមើលឃើញទេ។

### ខ. ការរំលោភបំពានផ្លូវអារម្មណ៍

ការរំលោភបំពានផ្លូវអារម្មណ៍គឺជាការប្រព្រឹត្តទង្វើដោយពាក្យសម្តី ឬកាយវិការមិនសមរម្យចំពោះកុមារ ឬលំនាំនៃការខកខានជាប្រចាំក្នុងការផ្តល់ឱ្យកុមារនូវការមើលថែគ្រប់គ្រាន់មិនទាក់ទងនឹងរាងកាយ និងខាងផ្លូវអារម្មណ៍។ ទង្វើបែបនេះអាចនឹងបង្កអន្តរាយយ៉ាងខ្លាំងដល់ការគោរពខ្លួនឯងរបស់កុមារ ឬសមត្ថភាពខាងសង្គម។

### គ. ការធ្វេសប្រហែស

ការធ្វេសប្រហែសគឺជាការខកខានក្នុងការផ្តល់ឱ្យកុមារ (នៅពេលដែលអាចធ្វើទៅបាន) នូវលក្ខខណ្ឌនានាដែលត្រូវបានទទួលស្គាល់ជាលក្ខណៈវប្បធម៌ថាមានសារសំខាន់សម្រាប់ការលូតលាស់ និងសុខុមាលភាពផ្លូវកាយ និងផ្លូវអារម្មណ៍។

### ឃ. ការប្រព្រឹត្តមិនត្រឹមត្រូវខាងផ្លូវភេទជាមួយកុមារ

ការប្រព្រឹត្តមិនត្រឹមត្រូវខាងផ្លូវភេទជាមួយកុមារ គឺជាទម្រង់នៃសកម្មភាពផ្លូវភេទណាមួយជាមួយកុមារ។ វាស្តែងឱ្យឃើញច្បាស់តាមរយៈសកម្មភាពរវាងកុមារ និងមនុស្សពេញវ័យ ឬកុមារដទៃទៀតដែលតាមអាយុ ឬការលូតលាស់ស្ថិតក្នុងទំនាក់ទំនងក្រោមការទទួលខុសត្រូវ សេចក្តីទុកចិត្ត ឬអំណាច សកម្មភាពដែលមានចេតនាដើម្បីបំពេញចំណង់ ឬសេចក្តីត្រូវការរបស់បុគ្គលម្នាក់ទៀត។ វាអាចមានជាអាទិ៍សកម្មភាពដែលមានការប៉ះពាល់ ឬមិនប៉ះពាល់ ការអន្ទង ឬការបង្ខំកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទណាមួយ ការប្រើប្រាស់កុមារដើម្បីប្រព្រឹត្តអំពើពេស្យាចារ ឬការប្រព្រឹត្តខាងផ្លូវភេទផ្សេងទៀត ឬការបង្ហាញដល់កុមារនូវសម្ភារតាមអ៊ិនធើណិតដែលមានលក្ខណៈកេងប្រវ័ញ្ចផ្លូវភេទ ការប្រើប្រាស់កុមារក្នុងការសម្តែង និងសម្ភារអាសអាភាស ឬថតរូបភាពកេងប្រវ័ញ្ចផ្លូវភេទ។

### ការអូសទាញ

ការអូសទាញ ជាទូទៅសំដៅទៅលើអាកប្បកិរិយាដែលបង្កលក្ខណៈងាយស្រួលដល់ជនល្មើសក្នុងការអូសទាញកុមារ ឬមនុស្សពេញវ័យដែលងាយរងគ្រោះដើម្បីបម្រើសកម្មភាពផ្លូវភេទ។ ជារឿយៗ វាទាក់ទងនឹងអំពើនៃការកសាងទំនុកចិត្តរបស់កុមារ និង/ឬអ្នកមើលថែរបស់ពួកគេ ឬមនុស្សពេញវ័យដែលងាយរងគ្រោះដើម្បីចូលទៅជិតពួកគេដើម្បីរំលោភបំពានផ្លូវភេទកុមារ។ ឧទាហរណ៍ ការអូសទាញរាប់បញ្ចូលទាំងការផ្តល់ ឬការយកចិត្តទុកដាក់ចំពោះកុមារ ឬមនុស្សពេញវ័យជាក់លាក់ណាមួយ ការផ្តល់អំណោយ ប្រាក់កាស គ្រឿងញៀន ឬគ្រឿងស្រវឹងដល់ពួកគេដែលជំរុញឱ្យមានអារម្មណ៍រ៉ូមែនទិក ឬបង្ហាញឱ្យពួកគេនូវគំនិតផ្លូវភេទតាមរយៈការសន្ទនា ឬការប៉ះពាល់នឹងរូបអាសអាភាស។

ការអូសទាញតាមអ៊ិនធើណិតគឺជាសកម្មភាពនៃការបញ្ជូនសារអេឡិចត្រូនិកបណ្ដុំសារ ឬការចូលរួមតាមបណ្ដាញអ៊ិនធើណិតជាមួយនឹងមាតិកាដែលអាចមានលក្ខណៈអសីលធម៌ ក្នុងគោលបំណងដើម្បីអូសទាញអ្នកទទួលព័ត៌មានឱ្យចូលរួម ឬចូលទៅក្នុងសកម្មភាពផ្លូវភេទជាមួយបុគ្គលផ្សេងទៀតពេលគឺអ្នកបញ្ជូនសារ។ល។

ទាំងកុមារ និងមនុស្សពេញវ័យដែលងាយរងគ្រោះអាចជាជនរងគ្រោះនៃការអូសទាញ និងការអូសទាញតាមអ៊ីនធើណិតដែលផ្ដោតគោលដៅលើកុមារ ជាពិសេសគឺអ្នកអូសទាញតាមអ៊ីនធើណិត។

## កិច្ចគាំពារ

វិធានការដែលយើងអនុវត្តដើម្បីទប់ស្កាត់ រាយការណ៍ និងឆ្លើយតបចំពោះការព្យាបាទ ឬការរំលោភបំពាន និងដើម្បីការពារសុខភាព សុខុមាលភាព និងសិទ្ធិមនុស្សរបស់អ្នកទាំងឡាយដែលមានទំនាក់ទំនងជាមួយអង្គការឃែរ មិនថាជាបុគ្គលិកអង្គការឃែរ និងបុគ្គលិកពាក់ព័ន្ធ ដៃគូ អ្នកចូលរួមគម្រោងកម្មវិធី និងសហគមន៍នោះទេ។

## អ្នកស្ម័គ្រចិត្តសហគមន៍

បុគ្គលទាំងឡាយដែលមកពីសហគមន៍មូលដ្ឋានដែលអង្គការឃែរ កំពុងធ្វើការជាមួយ និងអ្នកដែលបំពេញភារកិច្ចជូនអង្គការឃែរ ដោយស្ម័គ្រចិត្ត។

## អ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្ត

បុគ្គលណាមួយដែលទទួលបានគោលនយោបាយលើកទឹកចិត្តក្នុងការបំពេញភារកិច្ចជូនអង្គការឃែរ ជាបណ្ដោះអាសន្ន និងដោយស្ម័គ្រចិត្ត។ ជាឧទាហរណ៍ អ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្តអាចជាបុគ្គលក្នុងឋានៈជាជនភៀសខ្លួន ជនអន្តោប្រវេសន៍ ជនគ្មានផ្ទះសម្បែងក្នុងស្រុក និវត្តជន ឬសមាជិកសហគមន៍ម្ចាស់ផ្ទះដែលកំពុងបម្រើការងារឱ្យអង្គការឃែរ ដោយធ្វើការដើម្បីទទួលបានការតបស្នងជាគោលនយោបាយលើកទឹកចិត្ត។

## ភ្ញៀវទស្សនា

សំដៅទៅលើអ្នកទាំងឡាយដែលបានមកទស្សនកិច្ចនៅការិយាល័យ ឬគម្រោងកម្មវិធីរបស់អង្គការឃែរ រាប់បញ្ចូលទាំងតំណាងម្ចាស់ជំនួយ អ្នកសារព័ត៌មាន បណ្ដាញផ្សព្វផ្សាយ ក្រុមអ្នកស្រាវជ្រាវ បុគ្គលល្បីៗ សមាជិកគ្រួសារ។

## ឧបសម្ព័ន្ធ ៣

### សារតា

នៅខែធ្នូ ឆ្នាំ២០០៦ អង្គការថែរ អន្តរជាតិបានអនុម័តលើ "សេចក្តីថ្លែងការណ៍ស្តីពីការប្តេជ្ញាចិត្តលុបបំបាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទទាំងដោយបុគ្គលិករបស់ និងមិនមែនរបស់អង្គការសហប្រជាជាតិ " ដែលដាក់បញ្ចូលនូវបណ្តាបទដ្ឋានដើម្បីគាំទ្រដល់វឌ្ឍនភាពឆ្ពោះទៅរកការលុបបំបាត់ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទពីសំណាក់បុគ្គលិក។ ក្នុងឱកាសនោះដែរ អង្គការថែរ អន្តរជាតិ បានបញ្ជាក់អះអាងជាថ្មីពីគោលដៅរបស់ខ្លួនក្នុងការសម្រេចបានទាំងស្រុងនូវការអនុវត្តគោលការណ៍ស្នូលទាំង ៦ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០២ ដោយក្រុមការងាររបស់គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ (LASC) ទទួលបន្ទុកការទប់ស្កាត់ និងការឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។

នៅឆ្នាំ ២០០៩ អង្គការថែរ អន្តរជាតិបានបង្កើតគោលនយោបាយស្នូលដំបូងរបស់ខ្លួនស្តីពីកិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទដោយផ្អែកជាមូលដ្ឋានលើគោលការណ៍ស្នូល និងការប្តេជ្ញាចិត្ត។

នៅខែមីនា ឆ្នាំ២០១៧ អង្គការថែរ អន្តរជាតិបានពង្រីកវិសាលភាពគោលនយោបាយរបស់ខ្លួនស្តីពីកិច្ចការពារពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទដោយដាក់បញ្ចូលជាពិសេសនូវក្តីកង្វល់កាន់តែទូលំទូលាយស្តីពីការរំលោភបំពានលើកុមារ។ ការបញ្ជាក់អះអាងទាំងនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់អង្គការថែរ ក្នុងការទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ ព្រមទាំងការរំលោភបំពានលើកុមារពីសំណាក់បុគ្គលិកអង្គការថែរ និងបុគ្គលិកពាក់ព័ន្ធ ។

នៅខែតុលា ឆ្នាំ ២០១៩ អង្គការថែរ អន្តរជាតិបានពិនិត្យ និងពង្រីកវិសាលភាពគោលនយោបាយរបស់ខ្លួន រហូតដល់គោលនយោបាយកិច្ចគាំពាររបស់អង្គការថែរអន្តរជាតិនេះដែលកាន់តែមានលក្ខណៈទូលំទូលាយ (មានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១៥ ខែមេសា ឆ្នាំ ២០២០) ដោយបានដាក់បញ្ចូលនូវៈ

- កិច្ចការពារពីការបៀតបៀនផ្លូវភេទជាធាតុស្នូលនៃគោលនយោបាយ
- ការហាមឃាត់យ៉ាងតឹងរឹងលើបញ្ហាផ្លូវភេទរវាងបុគ្គលិកអង្គការថែរ និងបុគ្គលិកពាក់ព័ន្ធ និងអ្នកចូលរួមគម្រោងកម្មវិធី
- ការបញ្ជាក់យ៉ាងច្បាស់ថាអាពាហ៍ពិពាហ៍កុមារត្រូវបានហាមឃាត់
- ភ្ញៀវទស្សនា អ្នកស្ម័គ្រចិត្តសហគមន៍ និងអ្នកធ្វើការទទួលរបបគោលនយោបាយលើកទឹកចិត្តនៅក្នុងវិសាលភាពនៃការអនុវត្ត
- ការបញ្ជាក់យ៉ាងច្បាស់ថាគោលនយោបាយនេះមានវិសាលភាពអនុវត្តទាំងនៅក្នុង និងក្រៅម៉ោងធ្វើការ។
- វិធីសាស្ត្រផ្តោតលើជនរងគ្រោះរបស់យើងផ្តោតទៅលើការរក្សាការសម្ងាត់ជូនជនរងគ្រោះ និងអ្នកពាក់ព័ន្ធទាំងអស់។
- វិធីសាស្ត្រសុវត្ថិភាព និងកាត់បន្ថយហានិភ័យចំពោះកិច្ចការគាំពាររបស់យើង
- ការទទួលស្គាល់ពីកិច្ចសហការ និងការគាំទ្ររបស់យើងជាមួយបណ្តាដៃគូនានា។
- ការបញ្ជាក់យ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់អង្គការថែរ និងការធ្វើបរិយាប័ន្នក្រមប្រតិបត្តិស្តីពីកិច្ចគាំពារសម្រាប់បុគ្គលិក និង
- ការផ្លាស់ប្តូររចនាសម្ព័ន្ធដោយដាក់ក្រមប្រតិបត្តិស្តីពីកិច្ចគាំពារ កម្រងនិយមន័យ និងសារតាគោលនយោបាយជាឧបសម្ព័ន្ធ។